ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទំនាក់ទំនងរវាង

# មេធាវី ចៅក្រម និងព្រះរាជអាជ្ញា

ដោយ កែវ សុភា មេធាវីនៃក្រុមមេធាវីអាស៊ី

# ទំនាក់ទំនងរវាងមេធាវី ចៅក្រម និង ព្រះរាជអាជ្ញា

ដោយ**កែវ សុភា** មេធាវីនៃក្រុមមេធាវីអាស៊ីកម្ពុជា

មានសំណួរជាច្រើនដែលមិនទាន់មានចម្លើយតក្កបំផុតចំពោះទំនាក់ទំនងរវាងមេធាវី ចៅក្រម និង ព្រះរាជអាជ្ញា។ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈសេរី និង ឯករាជ្យដែលចូលរួមបំរើវិស័យយុត្តិធម៌[១]។ មេធាវី ចៅក្រម និង ព្រះរាជអាជ្ញា ជាសសរពាដ៏សំខាន់ ក្នុងចំណោមសសរនានាដែលទ្រទ្រង់កិច្ចការយុត្តិធម៌។ ក្នុងចំណោមសសរទាំងបីនេះ បើសសរណាមួយកោង ពុក ផុយ ខ្ទួតស៊ី ឬ បាក់ស្រុត សសរផ្សេងទៀតនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរ ហើយជាលទ្ធផលមិនអាចទ្រទ្រង់ខ្លួនឯង ក៏ដូចជាមិនអាចទ្រទ្រង់តួផ្ទះទាំងមូលបាន។ នៅព្រះរាជាណាចក្រកម្ពុជាមានមេធាវីសរុបទាំងកំពុងប្រកបរបរ សុំមិនប្រកបរបរ កំពុងធ្វើកម្ម សិក្សា និង សុំនៅក្រៅបញ្ជីសរុបចំនួន ៦២៧នាក់[២]។ **មេធាវី** គឺជាអ្នកដែលមានចំណេះដឹងអំពីច្បាប់ និង ជាអ្នកដែលទទួលការអនុញ្ញាតឬអាជ្ញាប័ណ្ណឱ្យប្រកបវិជ្ជាជីវៈផ្នែកច្បាប់[៣]។ មេធាវីធ្វើជាអ្នកតំណាង ឬ ជាអ្នកការពារកូនក្តីនៅចំពោះមុខអាជ្ញាធរ ឬ នីតិបុគ្គលនានា ដូចជាសាលាជំរះក្តី ក្រុមប្រឹក្សាវិន័យ និង នីតិបុគ្គលឯកជនជាអាទិ៍។ ក្រៅពីនេះ មេធាវីបំពេញកិច្ចការជាច្រើនទៀត ទាក់ទងនឹងវិស័យច្បាប់។ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈសេរីដែលប្រកបរបរទទួលទានចិញ្ចឹមជីវិតដោយមិនទទួលប្រាក់ខែពីរដ្ឋ ដូចជាចៅក្រម និង ព្រះរាជអាជ្ញាដែលទទួលប្រាក់ខែពីរដ្ឋតាមរយៈកិច្ចសន្យាគ្មានកាលកំណត់នោះឡើយ។ ចំណុចខុសគ្នាជាសំខាន់រវាងវិជ្ជាជីវៈរបស់ មេធាវី ចៅក្រម និងព្រះរាជអាជ្ញាស្ថិតនៅលើកិច្ចសន្យាការងារ និងសិទ្ធិអំណាចនៅក្នុងប្រព័ន្ធច្បាប់។ **ចៅក្រម** គឺជាមន្ត្រីសាធារណៈដែលទទួលការតែងតាំងឱ្យដឹកនាំគ្រប់គ្រងកិច្ចការច្បាប់ នៅសាលាជំរះក្តី[៤]។ នៅព្រះរាជាណាចក្រកម្ពុជា អ្នកមានងារជាចៅក្រម មិនត្រឹមតែបំរើការនៅ តាមសាលាជំរះក្តីទេ តែក៏ជាអ្នកបំរើការនៅតាមស្ថាប័ននីតិប្រតិបត្តិដូចជាក្រសួងយុត្តិធម៌ និង ជាអ្នកនយោបាយផងដែរ។ ចៅក្រម ជាអ្នកដឹកនាំនីតិវិធី និង ធ្វើការសំរេចចិត្តដោយផ្អែកលើឆន្ទានុសិទ្ធិរបស់ខ្លួន។ រីឯ**ព្រះរាជអាជ្ញា** គឺជាបុគ្គល ដែលមានភារកិច្ចនិងតួនាទីចោទប្រកាន់ក្នុងនាមរដ្ឋាភិបាល ទៅលើជនណាមួយ ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលជននោះបានប្រព្រឹត្ត[៥]។តួនាទី ភារកិច្ច និងបេសកកម្មលំអិតរបស់ចៅក្រម និង ព្រះរាជអាជ្ញា

---

[1] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

[2] បញ្ជីសមាជិកមេធាវី ២០០៩ ទំព័រ២៤២

[3] Black Law Dictionary, 1990, page 888

[4] Black Law Dictionary, 1990, page 841

[5] Black Law Dictionary, 1990, page 1221

ត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ទាក់ទងនឹងអង្គការចាត់តាំងតុលាការ និង បទដ្ឋានអន្តរជាតិពាក់ព័ន្ធ ។

ប្រព័ន្ធតុលាការ មានសារសំខាន់ជាងអ្វីទាំងអស់ក្នុងការផ្តល់នូវការការពារសិទ្ធិសេរីភាព។ ប្រព័ន្ធតុលាការធានាថាច្បាប់ និង បទបញ្ញាត្រូវបានអនុវត្តស្របទៅតាមស្មារតីនៃច្បាប់ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង វិធាននៃនីតិរដ្ឋត្រូវបានគោរព។ ចៅក្រម មេធាវី និងព្រះរាជអាជ្ញាត្រូវតែមានសេរីភាពក្នុងការអនុវត្តនូវវិជ្ជាជីវៈរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីផ្នែកនយោបាយ ។ អ្នកទាំងនោះត្រូវតែទទួលការការពារទាំងតាមផ្លូវច្បាប់ពីការវាយប្រហារ ការយាយី ឬ ការធ្វើទុក្ខទោស ទាំងតាមរយៈការអនុវត្តជាក់ស្តែងនៅពេលអនុវត្តនូវវិជ្ជាជីវៈរបស់ខ្លួនដើម្បីការពារសិទ្ធិរបស់អ្នកដទៃ ។ ចៅក្រម មេធាវី និងព្រះរាជអាជ្ញាគួរតែជាអ្នកការពារសិទ្ធិមនុស្សដ៏សកម្មដែលទទួលខុសត្រូវ ចំពោះប្រជាជន ហើយត្រូវប្រខ្ជាប់នូវកិរិតសីលធមិខ្ពស់បំផុត យោងទៅតាមច្បាប់ជាតិ ច្បាប់អន្តរជាតិ និង ក្រមសីលធមិរៀងៗខ្លួន។ ចៅក្រម មេធាវី និង ព្រះរាជអាជ្ញាទទួលបាននូវសិទ្ធិមនុស្សរបស់ខ្លួន ដូចជាមនុស្សឯទៀតដែរ ។ ដូច្នេះអ្នកទាំងនោះក៏ត្រូវតែទទួលបាននូវការការពិសេសដែរ ព្រោះពួកគេគឺជាអ្នកធានា ដ៏សំខាន់ចំពោះសិទ្ធិរបស់ប្រជាជន ។**ប្រសិនបើចៅក្រមមិនអាច**វាយតម្លៃអង្គហេតុ និងអនុវត្តច្បាប់ ប្រព័ន្ធយុត្តិធមិនឹងក្លាយទៅជាអំណាចដែលធ្វើអ្វីស្រេចតែចិត្ត (អត្តាធិបតេយ្យ) ។ **ប្រសិនបើមេធាវីមិនអាច**ធ្វើការប្រាស្រ័យទាក់ទងដោយសេរីជាមួយនឹងកូនក្តីរបស់ខ្លួន នោះគោលការណ៍សមភាពចំពោះមុខច្បាប់នឹងមិនត្រូវបានធានាឡើយ ។ **ប្រសិនបើព្រះរាជអាជ្ញាមិនទទួលបានការការពារ**នៅពេលអាយុជីវិតរបស់ខ្លួនស្ថិតក្នុងគ្រោះ ថ្នាក់ដោយសារការងាររបស់ខ្លួន នោះភារកិច្ចធ្វើការចោទប្រកាន់របស់ខ្លួននឹងត្រូវបានរងផលប៉ះពាល់។ នេះ គឺជាការការពារពិសេសសំរាប់ការបំពេញនូវការទទួលខុសត្រូវពិសេស។ នេះគឺជា**គោលការណ៍ស្តីពីឯករាជ្យភាព និង ភាពមិនលំអៀង**។ គោលការណ៍នៃឯករាជ្យភាពរបស់ចៅក្រមមិនមានគោលបំណងផ្តល់ឱ្យចៅក្រមនូវផលប្រយោជន៍ផ្ទាល់ខ្លួនទេ ប៉ុន្តែបើនិយាយឱ្យសមហេតុផលគឺដើម្បីការពារបុគ្គលនានាពីការបំពានសិទ្ធិអំណាច ។ ចៅក្រមមិនអាចសំរេចសេចក្តីតាមទំនើងចិត្ត ទៅតាមសេចក្តីលំអៀងរបស់ខ្លួន តែត្រូវអនុវត្តច្បាប់ទៅនឹងអង្គហេតឱ្យបានត្រឹមត្រូវ ។ ព្រះរាជអាជ្ញាមានភារកិច្ចស៊ើបអង្កេត និង ចោទប្រកាន់ការរំលោភសិទ្ធិ ដោយមិន រើសមុខថានរណាជាអ្នកប្រព្រឹត្តអំពើរំលោភបំពាននោះទេ។ ដោយឡែកមេធាវីត្រូវបំពេញការងាររបស់ខ្លួន ដើម្បីជាប្រយោជន៍របស់កូនក្តីខ្លួន។ យោងតាមច្បាប់អន្តរជាតិ សិទ្ធិទទួលបានការជំនុំជំរះពីសំណាក់តុលាការឯករាជ្យនិងមិនលំអៀងគឺជាសិទ្ធិដាច់ខាត ដែលមិនអាចឱ្យមានករណីលើកលែងឡើយ ។ ទោះជាក្នុងពេលមានសង្គ្រាម ឬ ពេលរដ្ឋ

ស្ថិតក្នុងគ្រាមានអាសន្នក្តី មានតែតុលាការដែលដំណើរការនីតិវិធីទៅតាមច្បាប់ និង គ្រប់គ្រងដោយវិធាន និង គោលការណ៍របស់ខ្លួនតែប៉ុណ្ណោះដែលអាចជំនុំជំរះ និង សំរេចដាក់ទោសជនណាមួយពីបទល្មើសព្រហ្មទណ្ឌ។ សរុបសេចក្តីមក *សិទ្ធិទទួលការជំនុំជំរះដោយយុត្តិធម៌នៅចំពោះមុខតុលាការឯករាជ្យ និង មិនលំអៀង មិនត្រឹមតែត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាអន្តរជាតិជាច្រើនទេ ប៉ុន្តែវាក៏ជា ផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិដែរ។ ហេតុនេះ ប្រទេសទាំងឡាយណាដែលមិនបានសុំចូលជាភាគីឬមិនបានឱ្យសច្ចាប័នសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធក៏ដោយ ក៏ជាប់កាតព្វកិច្ចគោរពសិទ្ធិខាងលើ និង ត្រូវរៀបចំឱ្យមានប្រព័ន្ធយុត្តិធម៌របស់ប្រទេសខ្លួនឱ្យបានសមស្រប*[6] ។ យោងតាមការអនុវត្តជាក់ស្តែងដែលស្ថិតនៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍ ចៅក្រម និងព្រះរាជអាជ្ញាមួយចំនួនមានបំណងរក្សានូវឯករាជ្យភាព និង ភាពមិនលំអៀងរបស់ខ្លួន។ ដំណាលគ្នានោះមានចៅក្រម និង ព្រះរាជអាជ្ញាមួយចំនួនធំផ្សេងទៀតមិនចង់បានឯករាជ្យភាពរបស់ខ្លួនទេ ដោយសារមានមូលហេតុអត្តនោម័ត និង សត្យានុម័តជាច្រើន។ ខ្លះយល់ថាខ្លួនត្រូវភ្ជាប់ខ្លួនទៅនឹងមជ្ឈដ្ឋានអ្នកមានអំណាចដើម្បីបានជាខែល នៅពេលមានបញ្ហាពាក់ព័ន្ធក្រមសីលធម៌ការឆ្វេសប្រហែស និង បទល្មើសពាក់ព័ន្ធនឹងការបំពេញមុខងារ និង ការប្រើប្រាស់សិទ្ធិអំណាច ជាអាទិ៍។ ខ្លះទៀតមានបំណងបង្កើតនូវបណ្តាញការពារក្រៅផ្លូវការ ដើម្បីទទួលបាននូវការការពារពេលមានបញ្ហាប្រឈមជាយថាហេតុពីប្រភពនានា។ ដូច្នេះ ឯករាជ្យភាពហាក់ដូចជាទ្រឹស្តីច្បាប់ដែលអាចអនុវត្តបានចំពោះតែកាលៈទេសៈមួយចំនួនតែប៉ុណ្ណោះ ។មានករណីខ្លះឯករាជ្យភាពត្រូវបានយកទៅប្រើប្រាស់ដោយគ្មានព្រំដែនកំណត់ច្បាស់លាស់។

មានគោលការណ៍មួយទៀតហៅថា " **គោលការណ៍ចៅក្រមធម្មជាតិ** " ដែលគោលការណ៍នេះមានមូលដ្ឋានចេញពីគោលការណ៍សមភាពចំពោះមុខច្បាប់ និង សមភាពចំពោះមុខតុលាការ ។ មានន័យថាគ្មានជនណាមួយត្រូវបានជំនុំជំរះក្រៅពីតុលាការ ឬ ចៅក្រមធម្មតា ដែលបានបង្កើតរួចជាស្រេច និង មានសមត្ថភាពនោះឡើយ ។ ភាពជាក់ស្តែងរបស់គោលការណ៍នេះគឺថា តុលាការសំរាប់គ្រាអាសន្ន តុលាការពិសេស តុលាការវិសាមញ្ញ និង តុលាការបែបប្រតិសកម្ម ត្រូវបានហាមឃាត់មិនឱ្យមាន។ មិនត្រូវច្រឡំការហាមឃាត់នេះជាមួយនឹងយុត្តាធិការឯកទេសលើប្រធានបទជាក់លាក់ណាមួយ ដូចជាតុលាការការងារ តុលាការរដ្ឋបាល តុលាការគ្រួសារ តុលាការពាណិជ្ជកម្មទេ។ នៅក្នុងរឿងព្រហ្មទណ្ឌ មានករណីលើកលែង

---

[6] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៧

ដោយផ្អែកលើប្រភេទភាគី  ដូចជាជនជាតិដើមភាគតិច និង អនីតិជន ជាដើម ។ មានប្រទេសជាច្រើនប្រើតុលាការយោធា ឬ តុលាការពិសេស  ដើម្បីកាត់ក្តីពលរដ្ឋស៊ីវិល ។ យោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប " *ចៅក្រមនៃតុលាការយោធា មិនអាចចាត់ទុកថាមានឯករាជ្យភាព និង មិនលំអៀងនោះទេ   បើយោងតាមចរិតនៃអង្គការរបស់ខ្លួន* " ។ គណៈកម្មាធិការសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋរបស់អាហ្វ្រិច បានធ្វើកំណត់សំគាល់ជាពិសេសថា " តុលាការយោធាត្រូវតែមានភាពឯករាជ្យ  មានការបើកចំហរ   អនុវត្តត្រឹមត្រូវតាមនីតិវិធី និង មានភាពយុត្តិធម៌  ដូចជាដំណើរការឯទៀតដែរ "[៧] ។

**មេធាវី** :

ដូចពោលពីខាងដើម  មេធាវី  ចៅក្រម និង ព្រះរាជអាជ្ញាជាសរសរ ឬ ជន្ទល់បីដែលទ្រទ្រង់ដល់វិស័យយុត្តិធម៌ និង នីតិរដ្ឋ ។  និយាយក្នុងក្របខណ្ឌសិទ្ធិសេរីភាព  មេធាវីដើរតួយ៉ាងសំខាន់ក្នុងការការសិទ្ធិសេរីភាព  ផលប្រយោជន៏ស្របច្បាប់ និង ធានាថាសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌ត្រូវបានគោរពតាមរយៈការការពារ និងធ្វើជាអ្នកតំណាងនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចនានាដូចជាតុលាការជាដើម ។

ក្នុងការការពារសិទ្ធិមនុស្ស  មេធាវីផ្តល់ការការពារប្រឆាំងនឹងការឃាត់ ឬ ឃុំខ្លួនតាមទំនើងចិត្តដោយធ្វើការដេញដោលពីការចាប់ឃុំខ្លួន  ក្នុងចំណោមកិច្ចការជាច្រើនទៀតទាក់ទងនឹងសិទ្ធិទាក់ទងនឹងនីតិវិធី ។ មេធាវីផ្តល់យោបល់ និង ការពារជនរងគ្រោះពីការរំលោភបំពានសិទ្ធិសេរីភាពពីសំណាក់ជនល្មើស ។ មេធាវីស្ថិតនៅក្នុងទីតាំងមួយដែលអាចលើកឡើងពីបញ្ហាអនីត្យានុកូលភាពនៃច្បាប់ណាមួយ  នៅចំពោះមុខតុលាការ  ប្រសិនបើប្រទេសនោះជាប្រទេសនីតិរដ្ឋពិត  ហើយតុលាការបំពេញមុខងារជាតុលាការពិត ។ សិទ្ធិត្រូវបានការពារ ឬតំណាងដោយមេធាវីគឺជាសិទ្ធិជាមូលដ្ឋាន  ដើម្បីឱ្យសំរេចបាននូវសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌  ដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ។

គោលការណ៏ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីមេធាវីចែងថា "  *ដើម្បីឱ្យជំនួយផ្នែកច្បាប់មានប្រសិទ្ធិភាព  ជំនួយនេះត្រូវតែបំពេញកិច្ចការដោយឯករាជ្យ ។ ការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានមានលក្ខណៈពេញលេញ  ទៅតាមអ្វីដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបាន  ដូចជាសិទ្ធិសេដ្ឋកិច្ច*

*សង្គម និង វប្បធម៌ ឬ សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មនុស្សគ្រប់រូបត្រូវតែទទួលបានប្រកបដោយប្រសិទ្ធភាពនូវសេវាផ្នែកច្បាប់ដែលផ្តល់ដោយ**អ្នកប្រកបវិជ្ជាជីវៈច្បាប់ឯករាជ្យ*** [8] ។

ដើម្បីឱ្យមេធាវីបំពេញមុខងារនិងវិជ្ជាជីវៈរបស់ខ្លួនបានដោយឯករាជ្យ រដ្ឋត្រូវការពារមេធាវីពីការជ្រៀតជ្រែកខុសច្បាប់ទៅក្នុងកិច្ចការរបស់មេធាវី ។ ការជ្រៀតជ្រែកទាំងនោះរួមមានការទាក់ទងជាមួយកូនក្តី ការគំរាមកំហែង និង ការបៀតបៀនលើរូបកាយ ជាអាទិ៍។ ក្រៅពីនេះការរំខាន ការយាយី និង ការព្រងើយកន្តើយមិនសហការ ពីសំណាក់មន្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ ក៏ជាឧបសគ្គធំធេងណាស់ដែរ ។

ច្បាប់ស្តីពីគណៈមេធាវីនៃប្រទេសអាហ្សែបៃហ្សាន(Azerbaijan)អាចបណ្តាលឱ្យមានការសំរបសំរួល(ការខូចខាត)ដល់សេរីភាពនិងឯករាជ្យភាពរបស់មេធាវីក្នុងការអនុវត្តមុខងារខ្លួន។ នៅប្រទេសលីប៊ី (Libya) សេរីភាពរបស់មេធាវីក្នុងការអនុវត្តវិជ្ជាជីវៈខ្លួនដោយសេរីដោយពុំបំរើការជាមន្ត្រីរាជការរដ្ឋ និងក្នុងការផ្តល់សេវាផ្នែកច្បាប់ស្ថិតក្នុងភាពមន្ទិល [9] ។ ច្បាប់អន្តរជាតិទទួលស្គាល់នូវសិទ្ធិរបស់មេធាវីក្នុងការទទួលនូវព័តមាននៅក្នុងសំណុំរឿង ដោយមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ ។

គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីមេធាវីចែងថា" *រដ្ឋាភិបាលត្រូវទទួលស្គាល់ និង គោរពយ៉ាងណាឱ្យការប្រាស្រ័យទាក់ទង និង ការពិគ្រោះ រវាងមេធាវីនិងកូនក្តី នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈត្រូវរក្សា**ការសម្ងាត់*** " ។ ឧបសគ្គមួយទៀតដែលមេធាវីជួបប្រទះគឺកង្វះការទទួលស្គាល់ពីសំណាក់ស្ថាប័ននានាដូចជាតុលាការជាដើម ។ វិធានខាងលើចែងថា"*គ្មានតុលាការ ឬអាជ្ញាធររដ្ឋបាលណាដែលថាច្បាប់បានទទួលស្គាល់សិទ្ធិមានមេធាវីនៅចំពោះមុខខ្លួន អាចបដិសេធមិនទទួលស្គាល់សិទ្ធិរបស់មេធាវីក្នុងការបង្ហាញខ្លួនដើម្បីជាប្រយោជន៍កូនក្តី នៅចំពោះមុខខ្លួនឡើយ លើកលែងតែមេធាវីនោះបាត់បង់គុណភាព ដោយអនុលោមទៅតាមច្បាប់ជាតិ...*" ។ គោលការណ៍នោះកំណត់ថា" *ពុំត្រូវកំណត់ថាមេធាវីដូចជាកូនក្តីរបស់មេធាវី ឬ ដូចជាបុព្វហេតុនៃកូនក្តីរបស់មេធាវី ដោយសារមេធាវីបំពេញមុខងាររបស់ខ្លួន*" ។

មេធាវីមាន**ភារកិច្ចខាងវិជ្ជាជីវៈ ចំពោះអតិថិជន(កូនក្តី) និង សហភាតា**។ គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីមេធាវីចែងថា : ភារកិច្ចរបស់មេធាវីរួមមាន (១) ផ្តល់ឱវាទដល់អតិថិជនអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អតិថិជនចំពោះមុខច្បាប់ របៀបដែលប្រព័ន្ធច្បាប់ដំណើរការ ក្នុងទំហំ

---

[8] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៦២

[9] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៦៣

ដែលពាក់ព័ន្ធ (២)ជួយអតិថិជនតាមរបៀបសមស្រប និង ចាត់វិធានតាមផ្លូវច្បាប់ការការពារផល ប្រយោជន៍របស់អតិថិជន និង (៣)ជួយអតិថិជននៅចំពោះមុខតុលាការ ឬ អាជ្ញាធររដ្ឋបាលនានា ទៅតាម ស្ថានភាពសមស្រប ។

ក៏ដូចជាចៅក្រម និង ពលរដ្ឋទាំងអស់ដែរ **សេរីភាពរបស់មេធាវីក្នុងការសំដែងមតិ និង បង្កើត/ចូលរួមសមាគមន៍**ជាលក្ខខណ្ឌសារវន្ត ដើម្បីឱ្យវិជ្ជាជីវៈច្បាប់ដំណើរការបានត្រឹមត្រូវ ។ នៅក្នុងកាលៈទេសៈខ្លះ មានការលំបាកក្នុងការញែកឱ្យដាច់ឆ្ងាយរវាង " *មេធាវីដែលជាប់ទាក់ទិននឹងការការពារសិទ្ធិរបស់អ្នកដែលមានចំណងទាក់ទងនឹងកិច្ចការនយោបាយ និងការចូលពាក់ព័ន្ធរបស់មេធាវីទៅក្នុងកិច្ចការនយោបាយ* " ។ *នៅក្នុងប្រទេសបេឡារុសនាពេលកន្លងមក ក្រឹត្យឆ្នាំ១៩៩៧ ស្តីពីសកម្មភាពមេធាវី និងសារការី បានប្រគល់សមត្ថកិច្ចឱ្យក្រសួងយុត្តិធម៌ផ្តល់ការអនុញ្ញាត(អាជ្ញាបណ្ណ) ឱ្យប្រកបវិជ្ជាជីវៈមេធាវី ហើយដើម្បីប្រកបរបរបាន តំរូវឱ្យមេធាវីចូលជាសមាជិកនៃអង្គការសហភាតាប្រមូលផ្តុំមួយដែលត្រួតត្រាដោយក្រសួងយុត្តិធម៌ ។ ដូច្នេះស្ថានភាពបែបនេះបានធ្វើឱ្យខូចឯករាជ្យភាពរបស់មេធាវី* " ។

មេធាវីដូចជាពលរដ្ឋដទៃដែរ ត្រូវមានការទទួលខុសត្រូវសាធារណៈ ហើយត្រូវប្រព្រឹត្តឱ្យស្របទៅតាមក្រមសីលធម៌ ។ បណ្តឹងប្រឆាំងនឹងមេធាវី ក្នុងក្របខណ្ឌវិជ្ជាជីវៈ ត្រូវដំណើរការឱ្យបានលឿន និងដោយយុត្តិធម៌ អនុលោមតាមនីតិវិធី ។ មេធាវីត្រូវមានសិទ្ធិទទួលបានការជំនុំជំរះមួយដែលយុត្តិធម៌ ក្នុងនោះរួមទាំងសិទ្ធិទទួលការពារពីមេធាវីណាមួយ តាមការជ្រើសរើសរបស់ខ្លួន[១០] ។

មេធាវីដើរតួនាទីដូចជាអ្នកការពារ/អ្នកស្នាក្តី និង ជាអ្នកផ្តល់យោបល់ប្រឹក្សានៅក្នុងសង្គម[១១] ។ ក្នុងតួនាទីជា**អ្នកស្នាក្តី** មេធាវីធ្វើជាអ្នកតំណាង/ជាអ្នកការពារក្តីឱ្យភាគីណាមួយនៅក្នុងបណ្តឹងអាជ្ញា និង បណ្តឹងរដ្ឋប្បវេណី ។ ក្នុងនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង មេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្តីខ្លួន ក្នុងទំហំដែលកូនក្តីរបស់ខ្លួនស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចសំរេច ។ ក្នុងតួនាទីជា**អ្នកផ្តល់យោបល់ប្រឹក្សា** មេធាវីផ្តល់យោបល់ដល់អតិថិជនទាក់ទងនឹងសិទ្ធិនិងកាតព្វកិច្ចរបស់អតិថិជន និង លើកឡើងនូវដំណោះស្រាយ/វិធានការទាក់ទងនឹងកិច្ចការជំនួញ និង បញ្ហាផ្ទាល់ខ្លួនរបស់អតិថិជន ។ នៅក្នុងសកម្មភាពទាំងពីរនេះ មេធាវីបកស្រាយច្បាប់និងអនុវត្តច្បាប់ទៅតាមស្ថានការជាក់ស្តែង ក្នុងទំហំនៃសិទ្ធិ និង កាតព្វកិច្ចរបស់ខ្លួន ។ មេធាវីធ្វើការស្រាវជ្រាវអំពីគោលបំណងនៃបទប្បញ្ញត្តិ

[10] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៦៨

[11] 1998-1999 Occupational Outlook Handbook (BLS), http://www.umsl.edu/services/govdocs

ច្បាប់ ដើម្បីសុំឱ្យមានការសំរេចសេចក្តីទៅតាមស្មារតីនៃច្បាប់ ។ សមត្ថភាពក្នុងការគិតរហ័ស សមត្ថភាពក្នុងការនិយាយដោយមានអំណាច និង ភាពថ្មឹកទាក់ទងនឹងវិធានសវនាការ/ជំនុំជំរះ ព្រមទាំងការមានយុទ្ធសាស្ត្រត្រឹមត្រូវ បទពិសោធការងារ គួបផ្សំនឹងវ័យ និង កាយសម្បទា ជាចំណុចសំខាន់សំរាប់ភាពជោគជ័យរបស់មេធាវី ។ មេធាវីត្រូវធ្វើបច្ចុប្បន្នភាពនូវចំណេះដឹងផ្នែកច្បាប់ជាប្រចាំ ។ មេធាវីត្រូវមានចំណេះដឹងទូទៅផ្នែកសង្គមឱ្យបានច្រើន ទើបមេធាវីនោះជាមេធាវីតាមនិយមន័យមេធាវី ។ មេធាវីដែលមានតែចំណេះដឹងផ្នែកច្បាប់មួយមុខមិនខុសពីកង្កែបនៅក្នុងអណ្តូង ។ ភាពជោគជ័យ ដោយសារការរត់ការការវាយឆ្នក់ និងការរួមគំនិតក្នុងសកម្មភាពខុសច្បាប់គឺ ជាជោគជ័យក្លែងក្លាយ ។

មេធាវីដែលចេះពិតប្រាកដគឺជាមេធាវីដែលចេះក្នុងវិស័យជាក់លាក់ ។ មេធាវីដែលចាត់ទុកថាខ្លួនចេះគ្រប់មុខគឺជាមេធាវីដែលនឹងមិនប្រាកដថាមានសមត្ថភាពយ៉ាងដូច្នោះទេ ។ មានមេធាវីមួយចំនួនប្រកាន់យកនូវជំនាញឯកទេសមួយច្បាស់លាស់ ខាងកិច្ចការសាធារណៈ និង កិច្ចការឯកជន ដែលរួមមានដូចជា :

- បរិស្ថាន ការចោលកាកសំណល់ ការបំពុលបរិស្ថាន ការបំផ្លាញសហគមន៍ ដីធ្លី សំណង់...
- សុខភាព (ឧទាហរណ៍ : ការត្រួតពិនិត្យថ្នាំជក់)
- ការការពារកុមារ ((ឧទាហរណ៍ : សុំកូន យុត្តិធម៌កុមារ សុខុមាលភាពកុមារ...)
- មជ្ឈតករ អាជ្ញាកណ្តាល ការចរចាជាមួយក្រុមសហជីព
- ពាណិជ្ជកម្ម ការបើកក្រុមហ៊ុន ការក្ស័យធន ការធានារ៉ាប់រង
- កម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ
- ការធ្វើកិច្ចសន្យាទិញលក់ដី-រថយន្ត រៀបចំមរតក/បណ្តាំ រៀបចំលិខិតស្នាម
- ការប្រថាប់ត្រាលើការបកប្រែ លើការថតចម្លង និង ធ្វើជាសាក្សីនៅក្នុងកិច្ចការជំនួញដូចជាកិច្ចសន្យាដាក់បញ្ចាំ ជាអាទិ៍
- បំរើការនៅតាមគ្រឹះស្ថានសិក្សា និង
- នៅក្នុងជួរជាអ្នកដឹកនាំធំៗរបស់ប្រទេស ដូចជានាយករដ្ឋមន្ត្រី ប្រធានាធិបតី និង រដ្ឋមន្ត្រី ។ល ។

មេធាវីអាចបំរើការពេញម៉ោង បំរើការទៅតាមម៉ោង និង បំពេញការងារទៅតាមកញ្ចប់ការងារណាមួយជាក់លាក់ ឱ្យអតិថិជនជារូបវន្ត និងនីតិបុគ្គល ទៅតាមរូបភាពណាមួយដូចជាមេធាវីប្រចាំក្រុមហ៊ុនមេធាវីបំរើការឱ្យរដ្ឋាភិបាល(ក្រុមប្រឹក្សាអ្នកច្បាប់) មេធាវីប្រចាំក្រសួងជំនាញណាមួយ និង មេធាវីប្រចាំគ្រួសារ ។ មានមេធាវីមួយក្រុមបំរើការឱ្យអង្គការនានាដើម្បីផ្តល់សេវាផ្នែកច្បាប់ដោយមិនយកកំរៃ ។

មានករណីខ្លះមេធាវីបំរើការឱ្យក្រុមហ៊ុន ឬ បំរើការជាក្រុម  ជាអ្នកផ្តល់សេវាផ្នែកច្បាប់ជូនជនក្រីក្រ ជនដែលទទួលអត្ថប្រយោជន៏តិចតួចពីសេវាសុខុមាលភាព  ដោយមិនយកកំរៃដែរ ។

តួនាទីមួយទៀតដែលសំខាន់របស់មេធាវីក្រៅពីជួយដល់ប្រព័ន្ធយុត្តិធមិក្នុងការស្វែងរកយុត្តិធមិ និង ជួយឱ្យមានតុល្យភាពខ្លះរវាងសិទ្ធិរបស់បុគ្គលឯកជននិងអំណាចរបស់ព្រះរាជអាជ្ញា  ព្រមទាំងអំណាចរបស់នគរបាលយុត្តិធមិ  គឺផ្តល់ការការពារជូនចៅក្រម និង ព្រះរាជអាជ្ញាដែលជាជនជាប់សង្ស័យ និងជាជនជាប់ចោទនៅក្នុងបទល្មើសនានា។

នៅក្នុងប្រទេសមួយចំនួន  *មេធាវីបំរើការជាអគ្គព្រះរាជអាជ្ញា  ជាព្រះរាជអាជ្ញា  និង ជាអ្នកស្នាក្តីសំរាប់ប្រយោជន៏សាធារណៈ ដែលបំរើការនៅតាមតុលាការនានា*[១២] ។ ចំណុចនេះមានភាពខុសគ្នាខ្លាំងដែលថានៅកម្ពុជាព្រះរាជអាជ្ញាពុំត្រូវបានចាត់ថ្នាក់ចូលក្នុងវិជ្ជាជីវៈមេធាវី  ដោយសារតែខ្លួនបំពេញកាតព្វកិច្ចក្នុងនាមជាភាគីម្ខាង( រដ្ឋ) និងដើម្បីផលប្រយោជន៏របស់ភាគីនោះ   តែបែរជាចាត់ទុកថាជាក្រុមចៅក្រម( ចៅក្រមឈរ) ដោយមិនបានទទួលស្គាល់ថាព្រះរាជអាជ្ញាឈរនៅក្នុងទីតាំងមួយដែលមិនអាចមិនលំអៀងបាន។ នៅក្នុងប្រទេសខ្លះ ដូចជាសហរដ្ឋអាមេរិចជាដើម  ចៅក្រមភាគច្រើនជាអតីតមេធាវី។ ច្បាប់របស់សហព័ន្ធ និង ច្បាប់របស់រដ្ឋនៃសហរដ្ឋអាមេរិច  បានតំរូវជាទូទៅថាចៅក្រមត្រូវតែជ្រើសតាំងចេញពីចំណោមមេធាវី។ ដោយឡែកមាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី *ចែងថា  " មិនចាំបាច់មានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាបត្រច្បាប់ :   ចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី៥ឆ្នាំនិងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់  ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ឆ្នាំ  អាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន "* ។ ច្បាប់នេះអាចឱ្យចៅក្រមក្លាយទៅជាមេធាវីដោយស្វ័យប្រវត្តិ  ដោយមានលក្ខខណ្ឌអនុគ្រោះចំពោះចៅក្រម ។ផ្ទុយទៅវិញ  ច្បាប់នេះមិនបានអនុញ្ញាតឱ្យមេធាវីអាចក្លាយទៅជាចៅក្រមដោយស្វ័យប្រវត្តិទេ។ ប្រសិនបើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានធ្វើវិសោធនកម្មដើម្បីឱ្យមានសមធមិកាន់តែច្រើនជាងមុន និង ដើម្បីឱ្យប្រព័ន្ធតុលាការមានចៅក្រមនិងព្រះរាជអាជ្ញាដែលជ្រើសរើសចេញពីមេធាវីដែលមានគុណធមិ និងមានបទពិសោធន៏ច្រើនឆ្នាំក្នុងវិស័យច្បាប់និងកិច្ចការតុលាការនោះយើងអាចកាត់បន្ថយនូវកំហុសឆ្គងដែលអាចនឹងបណ្តាលមកពីការសំរេចសេចក្តីដោយចៅក្រមវ័យក្មេងដែលពុំទាន់បានទទួលបទពិសោធន៏។ ក្រៅពីនេះ ការធ្វើវិសោធនកម្មអាចធ្វើឱ្យតួអង្គទាំងបីនៃប្រព័ន្ធយុត្តធមិ ( ចៅក្រម  ព្រះរាជអាជ្ញា និង មេធាវី)  ចេះឱ្យតម្លៃ និង គោរពគ្នាទៅវិញទៅមក ។ដំណាលគ្នានេះ  យើងគួរ

---

[12] 1998-1999 Occupational Outlook Handbook (BLS), http://www.umsl.edu/services/govdocs

ពង្រឹងការចូលប្រកបវិជ្ជាជីវៈមេធាវី តាមស្មារតីនៃមាត្រា៣២ខាងលើ ដើម្បីធានាថាវិជ្ជាជីវៈមេធាវីមិនមែនជាមណ្ឌលចាស់ជរាឬឃ្លាំងស្តុក ចៅក្រម ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី ដែលរដ្ឋឈប់ត្រូវការនោះទេ។

នៅក្នុងទំនាក់ទំនងរវាងមេធាវី និង មេធាវី មនុស្សមិនតិចទេដែលមានការយល់ច្រឡំថា ហេតុអ្វីបានជានៅពេលខ្លះគេឃើញមេធាវីតឹងសសៃកដាក់គ្នា ហើយស្រាប់តែក្រោយមកបែរជានិយាយលេងសើចសំណេះសំណាលគ្នា។ តាមការពិតប្រសិនបើមេធាវីម្ខាងៗមានទំនាក់ទំនងគ្នាល្អ នោះអត្ថប្រយោជន៍នឹងបានកាន់តែប្រសើរទៅភាគីទាំងសងខាងនៃរឿងក្តី។ តាមរយៈការជួបគ្នា ការផ្លាស់ប្តូរពត៌មានគ្នា និង ការចរចារគ្នា (ជាពិសេសក្នុងរឿងរដ្ឋប្បវេណី) មេធាវីម្ខាងៗកាន់តែរៀបចំខ្លួនបានល្អសំរាប់សវនាការ។ ផ្ទុយទៅវិញប្រសិនបើមេធាវីម្ខាងជាមេធាវីមានអធ្យាស្រ័យល្អ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ រីឯម្ខាងទៀតជាមេធាវីប្រភេទកាប់ដាវ នោះប្រយោជន៍របស់កូនក្តីដែលពឹងពាក់មេធាវីកាប់ដាវប្រាកដជាមានផលប៉ះពាល់ជាអវិជ្ជមាន។ មេធាវីជាមនុស្ស ដូច្នេះតែងតែមានអាកប្បកិរិយា និងឥរិយាបទផ្សេងៗពីគ្នា ដូច្នេះរបៀបរបបធ្វើការក៏ផ្សេងៗពីគ្នាដែរ។ កំហឹងធ្វើឱ្យមេធាវី រួមទាំងចៅក្រម និង ព្រះរាជអាជ្ញា ខូចខាតដល់សុភវិនិច្ឆ័យរបស់ខ្លួន។ អតិថិជនមួយចំនួនយល់ថាមេធាវីដែលធ្វើការស្ងប់ស្ងៀម នឹងធឹង និង មិនអួតឆ្កាដៃឆ្កាជើងជាមេធាវីមិនពូកែ។ អតិថិជនខ្លះរីករាយនៅពេលឃើញមេធាវីរបស់ខ្លួនប្រើសំដីវាយប្រហារលើដៃគូបដិបក្ស។ ភាពក្រេវក្រោធ និង ការប្រើពិធីសាស្រ្តយកកំហឹងជាគោល នៅក្នុងវិជ្ជាជីវៈ តុលាការ ឬ វិជ្ជាជីវៈមេធាវីមិនគ្រាន់តែជាការខុសឆ្គងផ្នែកវិជ្ជាជីវៈទេ តែថែមទាំងជាការទន់ខ្សោយខាងទំនាក់ទំនង និង សីលធម៌។ ការបំភិតបំភ័យមិនប្រាកដថាបានជោគជ័យទេ។ ការរក្សាភាពស្ងប់ស្ងៀម និង មានការគួរសមនៅចំពោះមុខឥរិយាបទមិនសមរម្យ ជាមធ្យោបាយល្អបំផុតក្នុងការទទួលជ័យជំនះក្នុងការដោះស្រាយរឿង ឬ ក្នុងសវនាការ។

ទំនាក់ទំនងរវាងមេធាវីនិងចៅក្រម អាចមានរូបភាពជាទំនាក់ទំនងវិជ្ជមាន និង ទំនាក់ទំនងអវិជ្ជមាន។ តាមការអះអាងរបស់លោកហ្សាងហ្វុយសិន(Zhang Fusen) រដ្ឋមន្រ្តីក្រសួងយុត្តិធម៌របស់ចិននៅប្រទេសចិន ទោះបីជាមេធាវីចិនភាគច្រើននៅក្នុងចំណោមមេធាវីចំនួន១០០០០នាក់ ជាមេធាវីប្រកបវិជ្ជាជីវៈត្រឹមត្រូវ ក៏ប៉ុន្តែមេធាវីមួយចំនួននៅតែចំណុះលើសំណូកដើម្បីឈ្នះក្តី។ នេះជាទំនាក់ទំនងផ្តើមចេញពីផលប្រយោជន៍ទាំងសងខាង។ ក្រៅពីនេះ បញ្ហាគម្លាតប្រាក់ខែឬប្រាក់ចំណូលរវាងចៅក្រម ព្រះរាជអាជ្ញា និង មេធាវី ព្រមទាំងការប្រឹងរត់ឱ្យទាន់ជីវភាពប្រណិតបែបអភិជន ក៏ជំរុញឱ្យមានទំនាក់ទំនងអវិជ្ជមាន។

មានចៅក្រម ព្រះរាជអាជ្ញា និងមេធាវីច្រើនលើសលុបខំប្រឹងដើម្បីដើរឱ្យទាន់ជីវភាពទាន់សម័យ ដែលធ្វើឱ្យខ្លួនភ្លេចមូលកភាព និង សមធម៌នៃវិជ្ជាជីវៈច្បាប់ ។

អាចមានករណីខ្លះដែលចៅក្រមនិងព្រះរាជអាជ្ញាមានការញញើតការប្តឹងរបស់មេធាវីទៅអាជ្ញាធរដែលមានសមត្ថកិច្ចពិនិត្យលើទង្វើរបស់ចៅក្រមនិងព្រះរាជអាជ្ញា ។ ទំនាក់ទំនងបែបនេះធ្វើឱ្យចៅក្រមនិងព្រះរាជអាជ្ញាយកចិត្តទុកដាក់ច្រើនជាងមុនទៅលើកិច្ចការរបស់ខ្លួន ក៏ប៉ុន្តែក៏ត្រូវបានមេធាវីអវិជ្ជាជីវៈមួយចំនួនទាញយកផលប្រយោជន៍ ។

## ចៅក្រម [១៣] :

ដើម្បីឱ្យការជំនុំជំរះមានភាពយុត្តិធម៌ ចៅក្រមជំនុំជំរះត្រូវតែឯករាជ្យ ។ សូម្បីតែសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការជំនុំជំរះដោយយុត្តិធម៌ត្រូវបានគោរព នៅខណៈដែលមានចៅក្រមជំនុំជំរះឯករាជ្យក៏ដោយ ក៏គេនៅតែចាត់ទុកថារដ្ឋបានបំពានកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនដែរ ប្រសិនបើប្រព័ន្ធយុត្តិធម៌មិនមែនជាអង្គការដែលមានអំណាចឯករាជ្យ ។ ដូច្នេះ**ឯករាជ្យភាព** សំដៅដល់ឯករាជ្យទាំងចៅក្រមជារូបវ័ន្តបុគ្គលដែលឯករាជ្យ ទាំងអង្គតុលាការទាំងមូលក្នុងលក្ខណៈជាស្ថាប័នដែលឯករាជ្យនៅក្នុងប្រព័ន្ធរបស់ខ្លួន និង នៅក្នុងទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗទៀត ។

សិទ្ធិទទួលបានការជំនុំជំរះមួយដែលយុត្តិធម៌តំរូវឱ្យចៅក្រម**មិនលំអៀង** ។ មានន័យថាទទួលការជំនុំជំរះដោយតុលាការមិនលំអៀង ពោលគឺចៅក្រមឬក្រុមសមូហភាពនៃចៅក្រមពុំមានផលប្រយោជន៍នៅក្នុងរឿងក្តី ហើយមិនមានគំនិតគិតជាមុនអំពីភាគីនានា ។ រឿងក្តីត្រូវបានសំរេចដោយផ្អែកលើអង្គហេតុ និងអនុលោមទៅតាមច្បាប់ ដោយពុំមានការដាក់កំហិត ។ *ភាពមិនលំអៀងរបស់តុលាការអាចត្រូវបានកំណត់ថាជាអវត្តមាននៃភាពលំអៀង ភាពអមិត្តឬភាពអនុគ្រោះចំពោះភាគីណាមួយ ។តុលាការត្រូវតែមិនលំអៀង និង ធ្វើឱ្យឃើញថាមិនលំអៀង ។ ដូច្នេះចៅក្រមមានភារកិច្ចចាកចេញពីរឿងក្តីដែលមានមូលហេតុគ្រប់គ្រាន់ដែលធ្វើឱ្យភាពលំអៀងរបស់ខ្លួនបង្កើតជាបញ្ហា* [១៤] ។

ទាក់ទងនឹង**ស្វ័យភាពហិរញ្ញវត្ថុនិងធនធាន** ប្រព័ន្ធតុលាការត្រូវការធនធានគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យបានសមស្រប ។ នៅព្រះរាជាណាចក្រកម្ពុជាតុលាការទទួលធនធានដែលកំណត់ និងផ្តល់ឱ្យ

[13] ឯកសារដដែល ទំព័រ១៥

[14] ឯកសារដដែល ទំព័រ៣០

ដោយអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ ។ ការពុំទទួលបានធនធានគ្រប់គ្រាន់អាចធ្វើឱ្យប្រព័ន្ធតុលាការងាយទទួលរងគ្រោះពីអំពើពុករលួយដែលធ្វើឱ្យចុះខ្សោយនូវឯករាជ្យភាព និង ភាពមិនលំអៀងរបស់ខ្លួន ។ ក្នុងការកំណត់នូវធនធានសំរាប់ប្រព័ន្ធតុលាការហាក់ដូចជាស្ទើរតែគ្មានការពិគ្រោះយោបល់ទូលំទូលាយជាមួយចៅក្រម ។ មធ្យោបាយដ៏មានប្រសិទ្ធិភាពដែលគេនិយមអនុវត្តដើម្បីធ្វើការត្រួតត្រាស្ថាប័ននានា គឺតាមរយៈការដាក់កំហិតលើធនធានហិរញ្ញវត្ថុ ។ នៅពេលធនធានត្រូវបានផ្តល់ ធានធានទាំងនោះត្រូវតែទទួលបាននូវការការពារពីការប្រើប្រាស់ពុំត្រឹមត្រូវ ។ ការលៃបំរុងទុកឬការដកហូតធានធានមកវិញក្នុងលក្ខណៈជាមធ្យោបាយធ្វើការត្រួតត្រាមិនត្រឹមត្រូវមិនគួរឱ្យកើតឡើងទេ ។ប្រាក់ខែចៅក្រមនិងព្រះរាជអាជ្ញាខ្ពស់ពុំគួរក្លាយជាមូលហេតុនៃប្រៀបធៀប និង តម្រឹមឱ្យដូចជាមន្ត្រីឬពលរដ្ឋធម្មតានោះឡើយ ។ ប្រសិនបើចៅក្រមនិងព្រះរាជអាជ្ញាក្នុងចំនួនដ៏តិចតួចទទួលប្រាក់ខែខ្ពស់ តែសំរេចបាននូវភាពយុត្តិធមិខ្ពស់បំផុតសំរាប់ប្រទេសជាតិទាំងមូល នោះគឺជាអ្វីដែលយើងត្រូវសាទរអំពីការប្រែប្រួលជាវិជ្ជមានជាប្រវត្តិសាស្រ្តពិត១ដែលមិនធ្លាប់មានពីមុនមកនៅកម្ពុជា ។ ឱ្យតែក្រពះឃ្លាន ចិត្តមុខជាហ៊ានធ្វើអ្វីមួយដែលមិនប្រាកដស្របនឹងមនសិការរបស់ខ្លួនឡើយ ។

ចៅក្រមត្រូវមាន**សិទ្ធិសេរីភាពមូលដ្ឋាន**មួយចំនួនទៀតដូចជាពលរដ្ឋដទៃ ។ យោងតាមតួនាទីរបស់ខ្លួននៅក្នុងប្រព័ន្ធយុត្តិធមិ សេរីភាពក្នុងការបញ្ចេញមតិ និង បង្កើតសមាគមន៏មានសារសំខាន់ជាទីបំផុតដោយលៃយ៉ាងណាកុំឱ្យសេរីភាពនោះធ្វើឱ្យខូចខាតដល់ឯករាជ្យភាពនិងភាពមិនលំអៀងរបស់ខ្លួន ។ ក្នុងអត្ថន័យនេះ ចៅក្រមអាចមានសិទ្ធិបង្កើតសមាគមន៏ចៅក្រមដើម្បីពង្រឹងវិជ្ជាជីវៈខ្លួន ។ *ចៅក្រមគួរត្រូវបាន**តែងតាំង**ដោយផ្អែកលើសមត្ថភាពវិជ្ជាជីវៈ តាមនីតិវិធីដែលមានតម្លាភាព ។ ទោះបីជាបទដ្ឋានអន្តរជាតិពុំបានហាមឃាត់ការតែងតាំងដោយអំណាចនីតិប្រតិបត្តឬអំណាចនីតិបញ្ញត្តិក្តី ជាការប្រសើរបើចៅក្រមត្រូវបានជ្រើសរើសដោយអង្គការឯករាជ្យដែលការគិតគួរជាលក្ខណៈនយោបាយពុំបានដើរតួនាទីក្នុងដំណើរការជ្រើសរើសនោះ ។ ទោះបីជាអង្គការដែលជ្រើសរើសចៅក្រមជាអង្គការបែបណាក៏ដោយ លទ្ធផលនៃការជ្រើសរើសត្រូវតែធានាថាបេក្ខជនដែលបានទទួលការតែងតាំងទៅក្នុងប្រព័ន្ធតុលាការគឺជាអ្នកដែលមានជំនាញចាំបាច់និង មានឯករាជ្យភាព*[១៥] ។

លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌមូលដ្ឋានដើម្បីឱ្យចៅក្រមទទួលបានឯករាជ្យភាពគឺ**ស្ថិរភាពនៃតំណែង** ។ ដរាបណាតំណែងចៅក្រមមិនមានស្ថិរភាពយូរអង្វែង នោះចៅក្រមងាយនឹងទទួលរងនូវសម្ពាធពី

[15] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៤៦

ផ្នែកផ្សេងៗទៀត ជាពិសេសផ្នែកដែលធ្វើការពិនិត្យមើលឡើងវិញនូវប្រអប់តំណែង។ ***ការធ្វើសេចក្តីសំរេចតំឡើងសក្តិឱ្យចៅក្រម****ក៏ត្រូវផ្អែកលើមូលដ្ឋាននៃលក្ខណវិនិច្ឆ័យដូចការជ្រើសតាំងដែរ ពោលគឺត្រូវតែជាលទ្ធផលនៃតម្លាភាព និង ដំណើរការជ្រើសរើសដោយយុត្តិធម៌*[16] ។

ឯករាជ្យភាពនៃតុលាការក៏អាចត្រូវបានចៅក្រមមួយចំនួនប្រើប្រាស់ជាខែលដើម្បីលាក់បាំងអាកប្បកិរិយាមិនស្របនឹងក្រមសីធមិជាយថាហេតុដែរ។ ហេតុនេះចៅក្រមត្រូវប្រព្រឹត្តដោយអនុលោមទៅតាមគោលការណ៍ណែនាំនៃក្រមសីលធម៌។ ប្រទេសមួយចំនួនរៀបចំក្រមសីលធម៌សំរាប់ចៅក្រមដោយឱ្យចៅក្រមធ្វើជាអ្នកព្រាង រីឯអំណាចនីតិប្រតិបត្តិជាអ្នកផ្តល់មតិបន្ថែម។ **ការទទួលខុសត្រូវ**របស់តុលាការ ជាការទទួលខុសត្រូវក្នុងការបំពេញមុខងារនៅក្នុងក្របខណ្ឌវិជ្ជាជីវៈដែលត្រូវស្ថិតនៅក្រោមវិធាននៃក្រមសីលធម៌។ ដោយឡែកការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌរបស់ចៅក្រមដែលបានប្រព្រឹត្តក្នុងលក្ខណៈជារូបវន្តបុគ្គលឯកជន វិធានដែលត្រូវអនុវត្ត គឺជាវិធានដែលអនុវត្តចំពោះបុគ្គលផ្សេងៗទៀតជាធម្មតា។ *ច្បាប់អន្តរជាតិបានកំណត់យ៉ាងច្បាស់ថាចៅក្រមអាចត្រូវបានដកហូតពីដំណែង លុះត្រាបានប្រព្រឹត្តខុសនឹងកិរិយា ឬអសមត្ថភាព យ៉ាងធ្ងន់ធ្ងរតែប៉ុណ្ណោះ។ វិធានការវិន័យចំពោះចៅក្រមត្រូវអនុវត្តដោយអង្គការឯករាជ្យ និងមិនលំអៀង និងត្រូវគោរពឱ្យបានទាំងស្រុងទៅតាមការធានាផ្នែកនីតិវិធី*[17] ។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ចម្លើយចំពោះសំណួរថាអង្គការឯករាជ្យ និង មិនលំអៀងមានរូបរាងពិតដែរឬទេនោះ វាស្ថិតនៅតែជាការប្រឹងប្រែងដើម្បីស្វែងរកចម្លើយនិងការអនុវត្តជាក់ស្តែង។

នៅសហរដ្ឋអាមេរិច ចៅក្រមត្រូវបានតែងតាំងមួយជីវិតដោយប្រធានាធិបតី ដោយមានការយល់ព្រមពីព្រឹទ្ធសភា។ នៅព្រះរាជាណាចក្រកម្ពុជា *ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកសម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់អោយនៅទំនេរ ការដាក់អោយនៅក្រៅក្របខ័ណ្ឌ ការហូតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ*[18] ។ ដូច្នេះយើងឃើញថាជាទូទៅអ្នកដែលធ្វើការតែងតាំងចៅក្រម ឬបណ្តុះបណ្តាលចៅក្រម មិនមែនជាអំណាចនីតិវិនិច្ឆ័យទេ តែជាអំណាចនីតិប្រតិបត្តិ។

---

[16] ឯកសារដដែល ទំព័រ៥១

[17] ឯកសារដដែល ទំព័រ៦០

[18] មាត្រា១១ ច្បាប់ស្តីពីការរៀបចំនិងការព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ទំនាក់ទំនងរវាងចៅក្រម មេធាវី និង ព្រះរាជអាជ្ញា ក្នុងរូបភាពជាញាតិ ជាសហព័ទ្ធ និង ជាសហាយស្មន់អាចបណ្តាលឱ្យការស្វែងរកយុត្តិធម៌មិនមានភាពស្រអាប់ ។ នៅព្រះរាជាណាចក្រកម្ពុជាមានករណីមួយចំនួនដែលថាប្រពន្ធឬប្តីជាចៅក្រម/ព្រះរាជអាជ្ញា ហើយសហព័ទ្ធម្ខាងទៀតជាមេធាវីឬជាព្រះរាជអាជ្ញាឬចៅក្រម ។ មានករណីខ្លះបុព្វញាតិជាចៅក្រម/ព្រះរាជអាជ្ញា រីឯកូនជាមេធាវី ។ មានករណីដែលឪពុក ឬម្តាយជាចៅក្រម ឬព្រះរាជអាជ្ញានៅតុលាការជាន់ខ្ពស់ រីឯកូនជាចៅក្រមឬព្រះរាជអាជ្ញានៅសាលាដំបូង ។ ករណីបែបនេះអាចបណ្តាលឱ្យការអនុវត្តនីតិវិធី ឬលទ្ធផលនៃការជំនុំជំរះក្តី មានផលប៉ះពាល់អវិជ្ជមាន ។ នៅសហរដ្ឋអាមេរិចធ្លាប់ មានករណីដែលចៅក្រមម្នាក់ឈ្មោះវែឡាស្យូហូឡែន(Verla Sue Holland) និងព្រះរាជអាជ្ញាឈ្មោះ ថុមអូខននីល( Tom O’Connel )មានទំនាក់ទំនងស្នេហាជាសហាយនឹងគ្នា ។ អ្នកទាំងពីរជំនុំជំរះរឿងក្តីឃាតកម្មគិតទុកជាមុនដែលត្រូវទទួលទោសប្រហារជីវិត ។ មានបញ្ហាចោទដែលលើកឡើងដោយមេធាវីជុំវិញបញ្ហាដែលថាទំនាក់ទំនងផ្ទាល់ខ្លួនមានផលប៉ះពាល់ដល់លទ្ធផលនៃការជំនុំជំរះ[១៩] ។

មានមូលហេតុដូចខាងក្រោមដែលអាចឱ្យមានការប្តឹងជំទាស់ចៅក្រមអាសន :[២០] :

-កាលណាចៅក្រមឬសហព័ទ្ធរបស់ចៅក្រមឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី

-កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ភាគីណាមួយ

-កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ

-កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយ ភាគីណាមួយ

-កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី

-កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ឬ

-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី ។

មូលហេតុប្តឹងជំទាស់ខាងលើអនុវត្តបានតែចំពោះទំនាក់ទំនងរវាងចៅក្រមនិងភាគីនៃរឿងក្តី ប៉ុន្តែមិនមានវិធានណាមួយដែលគ្របដណ្តប់ទំនាក់ទំនងរវាងមេធាវី ចៅក្រម និង ព្រះរាជអាជ្ញាឡើយ ។ ប្រទេស

---

[19] The New York Time: Texas Inmate Says Judge and Prosecutor Had Affair, June, 13, 2008.

[20] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៥៦

មួយចំនួនដូចជាសហរដ្ឋអាមេរិចជាដើមកំណត់មូលហេតុដិតចិត្តដោយឈរលើមូលដ្ឋានផលប្រយោជន៍ដែលមានលក្ខណៈ " **ផ្ទាល់** " និង " **ជាផលប្រយោជន៍ប្រាក់កាស** " [២១] ។

មានបញ្ហាមួយផ្សេងទៀតជុំវិញទំនាក់ទំនងជាដៃគូសហការរវាងចៅក្រម/ព្រះរាជអាជ្ញានិងមេធាវី ។ មានករណីដែលថាចៅក្រមឬព្រះរាជអាជ្ញាប្រាប់ឱ្យភាគីនៃរឿងក្តីណាមួយទៅរកឬបញ្ជូនរឿងក្តីណាមួយទៅឱ្យមេធាវីណាមួយដែលជាដៃគូសហការឬជាមិត្តឬជាកូនឬជាញាតិក្នុងថ្នាក់ណាមួយរបស់ខ្លួន ឬត្រឡប់មកវិញមេធាវីរិះរកពិធីសាស្ត្រដើម្បីបញ្ជូនរឿងក្តីណាមួយទៅឱ្យចៅក្រមឬព្រះរាជអាជ្ញាណាមួយដែលខ្លួនងាយធ្វើការជាមួយឬមានសមានចិត្តល្អងាយនឹងសហការឬជាមិត្តឬជាញាតិ ។ល ។ កិច្ចសហការបែបនេះ ទោះជាឈរ ឬ មិនឈរលើផលប្រយោជន៍ណាមួយក្តី វាបង្កើតឱ្យមានភាពល្អក់កករនៅក្នុងប្រព័ន្ធយុត្តិធម៌ ។ បញ្ហាធ្ងន់ធ្ងរអាក្រក់ជាងនេះទៅទៀតគឺតួអង្គយុត្តិធម៌ដែលមានអំណាចឆន្ទានុសិទ្ធិ ដើរតួជាអ្នករត់ការនៅក្នុងប្រព័ន្ធយុត្តិធម៌ ប្រសិនបើប្រទេសណាមួយជាកំណត់នោះមិនមានប្រព័ន្ធយុត្តិធម៌ដែលបំរើគោលដៅយុត្តិធម៌ ។

ទំនាក់ទំនងពាណិជ្ជកម្មរវាងចៅក្រម/ព្រះរាជអាជ្ញានិងមេធាវីក៏ជាកត្តាគួរឱ្យព្រួយបារម្ភ ។ ឧបមាថាចៅក្រម/ព្រះរាជអាជ្ញាជួលផ្ទះឱ្យមេធាវីឬក្រុមមេធាវីបើកការិយាល័យ ឬរួមគ្នាបើកការិយាល័យឬរកជំនួញណាមួយ ហើយមេធាវីនោះនឹងឡើងតុលាការដើម្បីការពារក្តីនៅចំពោះមុខចៅក្រម/ព្រះរាជអាជ្ញានោះនៅក្នុងប្រទេសមួយចំនួនទំនាក់ទំនងបែបនេះពុំត្រូវបានអនុញ្ញាតឡើយ ដោយសារមានការព្រួយបារម្ភពីឯករាជ្យភាព និងភាពមិនលំអៀងរបស់ចៅក្រម/ព្រះរាជអាជ្ញា ។ ប្រសិនបើចៅក្រមជាសមាជិកភាគហ៊ុននៃក្រុមហ៊ុនណាមួយ ឬ សហព័ទ្ធ/បច្ឆាញាតិរបស់ចៅក្រមជានិយោជករបស់ក្រុមហ៊ុនឬអង្គការណាមួយ ប្រសិនបើចៅក្រមនោះជាអ្នកកាន់រឿងក្តីពាក់ព័ន្ធនឹងក្រុមហ៊ុនឬអង្គការខាងលើ នឹងមានបញ្ហាទំនាស់ផលប្រយោជន៍ជាមិនខាន ។

ប្រសិនបើចៅក្រម/ព្រះរាជអាជ្ញាមានកូនស្រី/ប្រុស ឬមេធាវីមានកូនស្រី/ប្រុស ហើយកូននោះឬចៅក្រម/ព្រះរាជអាជ្ញានោះ មានទំនាក់ទំងស្នេហាត្រឹមត្រូវដូចជាត្រូវជាគូដណ្តឹងឬកូនប្រសារឬឪពុកឬម្តាយក្មេក ឬអនាគតជាគូដណ្តឹងឬកូនប្រសារឬឪពុកឬម្តាយក្មេក ។ ទំនាក់ទំនងបែបនេះអាចចោទជាបញ្ហាដែរ ប្រសិនបើមេធាវីត្រូវបំពេញតួនាទីខ្លួននៅចំពោះមុខចៅក្រម/ ព្រះរាជអាជ្ញាពាក់ព័ន្ធ ។

ក្រៅពីឧទាហរណ៍ខាងលើ នៅមានកាលៈទេសៈជាច្រើនទៀតដែលប្រទេសមួយចំនួនកំណត់ថា ចៅក្រមត្រូវបាត់បង់គុណភាពក្នុងការកាន់រឿងទាំងនោះ ដូចជា :

[21] Ethics and the Lawyer/Judge Relationship, Chapter 24, John Hyde, 2004, p.3.

-ចៅក្រមបានឱ្យយោបល់ទៅភាគីម្ខាងទាក់ទងនឹងប្រធានបទតែមួយនៃបណ្តឹង

-ចៅក្រមធ្លាប់បានធ្វើជាអ្នកតំណាង( មេធាវី) ឱ្យប្តីនៅក្នុងរឿងលែងលះ( បាត់បង់គុណភាពធ្វើជាចៅក្រមនៅក្នុងរឿងរក្សាកូនដែលមានភាគីដដែល) ។ល ។

នៅក្នុងទំនាក់ទំនងជាមួយមេធាវី ចៅក្រមហាក់ដូចជាមានស្ថានភាពខាងឋានៈខ្ពស់ជាងព្រះរាជអាជ្ញា និងមេធាវី ទៅតាមរូបភាពផ្សេងៗតាំងពីកន្លែងអង្គុយ រហូតដល់សិទ្ធិសំរេច ។ តួអង្គយុត្តិធម៌ទាំងបីចេញពីមហាវិទ្យាល័យច្បាប់តែមួយ និងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញរយៈពេលប្រហាក់ប្រហែលគ្នា ។ ចំណុចខុសគ្នា នៅត្រង់សិទ្ធិសំរេចចុងក្រោយ រីឯចំណុចដូចគ្នាគឺសិទ្ធិស្នើសុំនិងសិទ្ធិប្តឹងទៅវិញទៅមកប្រសិនបើមានកំហុសនីតិវិធី កំហុសក្រមសីលធម៌ និង មូលហេតុផ្សេងទៀតដែលបញ្ញត្តិដោយច្បាប់ ។ នៅប្រទេសតៃវ៉ាន់មានជម្លោះដ៏ធំមួយទាក់ទងនឹងឋានៈរវាងចៅក្រមនិងព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាទាមទារឱ្យមានការប្រព្រឹត្តមកលើខ្លួនស្មើគ្នានឹងចៅក្រម ។ ចៅក្រម៦រូបត្រូវបានស៊ើបអង្កេតថាមានវត្តមាននៅក្នុងពិធីជប់លៀងមួយរបស់អ្នកជំនួញ នៅខែកក្កដា ឆ្នាំ១៩៩៨ ។ មួយថ្ងៃក្រោយពីប្រកាសដាក់ទោសចៅក្រមទាំងនោះ ក្រសួងយុត្តិធម៌ប្រកាសពីការចាត់វិធានការប្រឆាំងនឹងព្រះរាជអាជ្ញា៥រូបដែលចូលរួមពិធីជប់លៀងដដែលនោះ ក៏ប៉ុន្តែទោសស្រាលជាងចៅក្រមដោយគ្រាន់តែធ្វើការព្រមានដោយផ្ទាល់មាត់ ។ ដូច្នេះមានបញ្ហាចោទចំពោះការយោគយល់ដល់ព្រះរាជអាជ្ញាជាងចៅក្រម ។ ព្រះរាជអាជ្ញាលើកឡើងថា នៅក្នុងពិធីធម្មតានៃសង្គមដែលពុំមានទំនាស់ផលប្រយោជន៍ ពុំមានហេតុផលអ្វីមិនឱ្យព្រះរាជអាជ្ញាចូលរួមទេ ។ ចៅក្រមបានលើកឡើងថា" ចៅក្រមក៏ជាមនុស្សដែរ ។ ចៅក្រមត្រូវការបរិភោគ និង ត្រូវការមិត្តភក្តិ " ។ មានការលើកឡើងថា ពេលខ្លះចៅត្រូវគិតឱ្យបានដិតដល់មុននឹងសំរេចទទួលការអញ្ជើញពីមិត្តភក្តិចាស់ដែលខ្លួនមិនបានទាក់អស់ពេលជាយូរមកហើយ ។ ជាការពិតណាស់វិជ្ជាជីវៈចៅក្រមទាមទារឱ្យគោរពបទដ្ឋានមួយខុសពីជនទូទៅ ។ ការពិតនោះគឺថាចៅក្រម ត្រូវបានបង្ខំចិត្តរស់នៅដោយជីវិតក្រៀមក្រោះ ដើម្បីឆ្លើយតបទៅតាមក្រមសីលធម៌ជាចៅក្រម ។ ព្រះរាជអាជ្ញានៃតុលាការជាន់ខ្ពស់មួយរូបនៃប្រទេសតៃវ៉ាន់និយាយថា "*មហាជនទូទៅមានការរំពឹងទុកខ្ពស់លើចៅក្រម និងព្រះរាជអាជ្ញា ជាងវិជ្ជាជីវៈផ្សេងទៀត ។ នេះជាការមិនសមហេតុផលទាល់តែសោះ ។ ការទាមទារគួរតែអាស្រ័យទៅតាមកាលៈទេសៈ ដើម្បីកុំឱ្យយើងរស់នៅក្នុងជីវិតឯកោ*"[២២] ។ នៅព្រះរាជាណាចក្រកម្ពុជា បញ្ហាចៅក្រម និង ព្រះរាជអាជ្ញាបង្ហាញខ្លួននៅតាមហាងស៊ីផឹក តាមបា ខារ៉ាអូខេ និង កន្លែងមិនសមស្របផ្សេងទៀត ទោះបីជា ជាមួយគូក្តី ជាមួយសហការីខ្លួន ឬ

[22] TAIPEI TIMES, Scandal highlights conflict within the legal system, http://www.taipeitimes.com/News/local/archives/1999/11/28/12756

ជាមួយមេធាវីក្តី ហាក់ដូចជាពុំទាន់មានការហាមឃាត់ដោយច្បាប់ និង ពុំទាន់ជាចំណាប់អារម្មណ៍ខ្លាំងរបស់បណ្តាញសារពត៌មាននៅឡើយទេ ។ ទំនាស់ផលប្រយោជន៍ផ្ទាល់ដោយចេញមុខ ដូចឧទាហរណ៍ខាងលើក៏ពុំទាន់កើតមាននៅឡើយ ។ ក៏ប៉ុន្តែការស្ងៀមស្ងាត់មិនប្រាកដថា មិនមានសញ្ញាណាមួយនៃការកកើតវិវាទនោះទេ ។

**ព្រះរាជអាជ្ញា** :

ការគោរពសិទ្ធិសេរីភាព និង ភាពរឹងមាំនៃនីតិរដ្ឋ អាស្រ័យមួយផ្នែកធំទៅនឹងភាពរឹងមាំខ្លាំងក្លារបស់អាជ្ញាធរដែលមានតួនាទីចោទប្រកាន់ មានឯករាជ្យភាព និង មិនលំអៀង ។ មិនដូចជាមេធាវី និង ចៅក្រមឡើយ ច្បាប់អន្តរជាតិមិនមានបទប្បញ្ញត្តិណាមួយដែលធានានូវឯករាជ្យភាពនៃស្ថាប័នអយ្យការឡើយ ។ មូលហេតុគឺថា នៅក្នុងប្រព័ន្ធច្បាប់មួយចំនួន ព្រះរាជអាជ្ញាត្រូវបានតែងតាំងដោយអំណាចនីតិប្រតិបត្តិ ឬ ចំណុះថ្នាក់ណាមួយនៃអំណាចនីតិប្រតិបត្តិ ហេតុនេះហើយព្រះរាជអាជ្ញាត្រូវមានភារកិច្ចស្តាប់បង្គាប់របស់រដ្ឋាភិបាល ។ នៅក្នុងប្រទេសមួយចំនួនដូចជាម៉ិចស៊ិចជាដើម ឯករាជ្យភាពរបស់ព្រះរាជអាជ្ញាមានចោទជាបញ្ហា ។ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិចកាំង បានលើកឡើងពីការព្រួយបារម្ភទាក់ទងនឹងស្ថានការដែលថាកន្លែងធ្វើការរបស់ព្រះរាជអាជ្ញាស្ថិតនៅក្នុងមូលដ្ឋានយោធា ហើយធ្វើការដោយសហការស្និតនឹងយោធាធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ឯករាជ្យភាពរបស់ព្រះរាជអាជ្ញា និង ធ្វើឱ្យអំណាចនេះចំណុះគេ ។

យោងតាមគោលការណ៍ណែនាំស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញា រដ្ឋត្រូវធានាថា *បុគ្គលដែលត្រូវបានជ្រើសរើសឱ្យធ្វើជាព្រះរាជអាជ្ញាត្រូវតែជាបុគ្គលដែលមានសុចរិត និងមានសមត្ថភាព មានការបណ្តុះបណ្តាលត្រឹមត្រូវ និង មានគុណសម្បត្តិ ។ រដ្ឋត្រូវធានាថាព្រះរាជអាជ្ញាអាចបំពេញមុខងារវិជ្ជាជីវៈរបស់ខ្លួនបានដោយគ្មានការបំភិតបំភ័យ គ្មានឧបសគ្គ គ្មានការយាយី គ្មានការជ្រៀតជ្រែកដោយមិនត្រឹមត្រូវ ឬ ការដាក់ឱ្យទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌឬការទទួលខុសត្រូវផ្សេងទៀតដែលគ្មានហេតុផលសមស្រប ។ ព្រះរាជអាជ្ញា និងគ្រួសាររបស់ព្រះរាជអាជ្ញាត្រូវទទួលការការពារនៅពេលដែលសន្តិសុខរបស់ខ្លួនទទួលការគំរាមកំហែងដោយសារតែការបំពេញមុខងារចោទប្រកាន់*[២៣] ។ ការធានាមួយទៀតគឺព្រះរាជអាជ្ញាត្រូវទទួលបាននូវលក្ខខណ្ឌការងារសមស្រប មានប្រាក់ខែគ្រប់គ្រាន់ ហើយក្នុងករណីអនុវត្តបាន ត្រូវមានរយៈពេលកាន់ដំណែង ប្រាក់សោធននិវត្តន៍ និង អាយុចូលនិវត្តន៍ សមស្រប ។ ដូចជាចៅក្រមដែរ ព្រះរាជអាជ្ញាត្រូវបានឡើងឋានៈលក្ខណសម្បត្តិ សមត្ថភាព ភាពសុចរិត និង បទពិសោធន៍ វិជ្ជាជីវៈ ។

[23] គោលការណ៍ណែនាំរបស់អ.ស.ប ស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញា : គោលការណ៍ទី៥ ទី៦ ទី៧ និង ទី៨ ។

ដូចជាពលរដ្ឋឯទៀតដែរ ព្រះរាជអាជ្ញាមានសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ចូលជាសមាគមន៍ និង ធ្វើការប្រជុំគ្នា ។ ព្រះរាជអាជ្ញាមិនត្រូវរងការបាត់បង់អត្ថប្រយោជន៍នៃវិជ្ជាជីវៈដោយសារតែមូលហេតុនៃចំណាត់ការបណ្តឹងអាជ្ញា ឬ សមាជិកភាពរបស់ខ្លួននៅក្នុងអង្គការផ្នែកច្បាប់ឡើយ ។

គោលការណ៍ណែនាំខាងលើកំណត់ថា អង្គការអយ្យការត្រូវមានមុខងារដាច់ដោយឡែកទាំងស្រុងពីមុខងារតុលាការ ។ នៅក្នុងប្រព័ន្ធច្បាប់មួយចំនួនមានមុខងារមួយចំនួនដែលជាមុខងារតុលាការ ។ ឧទាហរណ៍ដូចជាការបង្គាប់ឱ្យឃុំខ្លួនដើម្បីបង្ការការរត់គេច ឬ ការប្រមូលភស្តុតាងជាដើម ។ គោលការណ៍ណែនាំ ទី១៥ ចែងថា ព្រះរាជអាជ្ញាត្រូវយកចិត្តទុកដាក់ធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយអ្នករាជការ ជាពិសេសអំពើពុករលួយ ការរំលោភបំពានអំណាច ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និង បទល្មើសព្រហ្មទណ្ឌផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ... ។ ព្រះរាជអាជ្ញាត្រូវបដិសេធមិនប្រើប្រាស់ភស្តុតាងដែលទទួលបានដោយសារការរំលោភបំពានសិទ្ធិមនុស្ស[២៤] ។

ចំពោះទំនាក់ទំនងរវាងព្រះរាជអាជ្ញានិងចៅក្រម និង ព្រះរាជអាជ្ញានិងមេធាវី សូមមើលការពន្យល់ខាងលើ ។ ចំពោះចំណុចដូចគ្នា និង ចំណុចខុសគ្នារវាងចៅក្រម ព្រះរាជអាជ្ញា និងមេធាវី រួមមានជាអាទិ៍ ៖

| | **ចៅក្រម** | **ព្រះរាជអាជ្ញា** | **មេធាវី** |
|---|---|---|---|
| **ចំណុចដូចគ្នា** | -ចំណេះទូទៅនីតិសាស្ត្រ<br>-ឯកទេសច្បាប់ | -ចំណេះទូទៅនីតិសាស្ត្រ<br>-ឯកទេសច្បាប់ | -ចំណេះទូទៅនីតិសាស្ត្រ<br>-ឯកទេសច្បាប់ |
| **ចំណុចខុសគ្នា** | -ភ្ជាប់ខ្លួននឹងរដ្ឋតាមរយៈកិច្ចសន្យាគ្មានកាលកំណត់<br>- ទទួលប្រាក់ខែពីរដ្ឋ<br>-សិទ្ធិសំរេច<br>-ឆន្ទានុសិទ្ធិច្រើន<br>-កំហិតសេរីភាពការងារ<br>-កំហិតទីកន្លែងការងារ<br>-ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមគ្រប់គ្រង | -ភ្ជាប់ខ្លួននឹងរដ្ឋតាមរយៈកិច្ចសន្យាគ្មានកាលកំណត់<br>-ទទួលប្រាក់ខែពីរដ្ឋ<br>-សិទ្ធិចោទប្រកាន់<br>-សិទ្ធិស្នើសុំដាក់ទោស<br>-កំហិតសេរីភាពការងារ<br>-កំហិតទីកន្លែងការងារ<br>-ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមគ្រប់គ្រង | -ជាវិជ្ជាជីវៈសេរី<br>-ទទួលថវិកាពីកូនក្តី<br>-សិទ្ធិស្នើសុំ<br>-សិទ្ធិប្តឹង/តវ៉ា<br>-សេរីភាពការងារ<br>-ទីកន្លែងណាក៏បាន<br>-មានគណៈមេធាវីគ្រប់គ្រង |

[24] International Principles on the Independence and Accountability of Judges, Lawyers and Prosecutors, 2004, ដោយ José Zeitune និង Federico Andreu-Guzman, ទំព័រ៧៤ និង ៧៧

សរុបសេចក្តីមកទំនាក់ទំនងរវាងចៅក្រម ព្រះរាជអាជ្ញា និង មេធាវី ជាទំនាក់ទំនងដែលអាស្រ័យគ្នាទៅវិញទៅមក។ ចៅក្រមប្រៀបបាននឹងចង្កូតរថយន្តដែលដឹកនាំយានយន្តយុត្តិធម៌ រីឯព្រះរាជអាជ្ញា និង មេធាវីប្រៀបបាននឹងហ្វ្រាំងទាំងសងខាងរបស់រថយន្ត។ នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការគោរពនិងចេះឱ្យតម្លៃគ្នាទៅវិញទៅមក មិនគ្រាន់តែជាបញ្ហាច្បាប់ទេ តែក៏ជាបញ្ហាសុជីវធម៌ចំពោះមនុស្សទូទៅ។

ចៅក្រម ព្រះរាជអាជ្ញា និង មេធាវី ជាវិជ្ជាជីវៈដែលមហាជនតែងតែសំឡឹងមើល។ អ្នកទាំងអស់នេះមិនមែនជាតួកុនឬជាតារាទេ តែជាប្រភេទមនុស្សដែលសង្គមជាតិបានបង់តម្លៃមួយមកឱ្យខ្លួន។ ចៅក្រម និង ព្រះរាជអាជ្ញាលើសលប់ ត្រូវបានមន្ត្រីរាជការទូទៅយល់ឃើញថាសង្គមបានបង់តម្លៃនៃការគោរពខ្ពស់ហួសហេតុ រហូតដល់អ្នកទាំងនោះធ្វើអ្វីដោយពុំសូវកោតក្រែង[២៥]។ ការកំណត់ឋានៈឱ្យចៅក្រមមានឋានៈសង្គមខ្ពស់ជាងវិជ្ជាជីវៈដទៃទៀតអាចបង្កើតឱ្យមានការរើសអើងបុគ្គលឈរលើស្ថានភាពតួនាទីក្នុងសង្គម។

ប្រសិនបើពេទ្យព្យាបាលមនុស្សម្នាក់មិនត្រឹមត្រូវ នោះអ្នកដែលរងគ្រោះមានតែម្នាក់តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមឬព្រះរាជអាជ្ញាសំរេចសេចក្តីខុសឬអយុត្តិធម៌ អ្នកដែលរងគ្រោះ និងទទួលទុក្ខទោស គឺជាក្រុមមនុស្សមួយក្រុម រាប់តាំងពីភាគី ឪពុកម្តាយ ជីដូនជីតា ។ល។

មេធាវីប្រៀបបាននឹងកូនឃ្មុំដ៏តូចមួយដែលប្រឹងប្រែងពាំនាំលំអងផ្កា និង ទឹកដមផ្លែឈើឬផ្កាមកដាក់ក្នុងផ្លិតដ៏ធំមួយរបស់អ្នកដទៃដែលមិនចេះពេញ។

មានការប្រៀនប្រដៅមួយដែលព្រះពុទ្ធសាសនាបានដាស់តឿនថា " **មនុស្សធ្លាក់ខ្លួន មិនមែនមកពីមនុស្សចង់ទទួលទានខ្លួនទេ តែក៏ព្រោះតែមកពីទទួលទានសាច់** " ដូច្នេះតួអង្គយុត្តិធម៌ទាំងបីគួរពិចារដោយមិន ចាំបាច់មានការបកស្រាយឡើយ។

---

[25] នេះជាការយល់ឃើញផ្ទាល់ខ្លួនរបស់អ្នកនិពន្ធតាមរយៈបទពិសោធន៍របស់ខ្លួនដែលបានដឹងឮពីមហាជន និង ដឹងឮតាមរយៈដំណើរទស្សកិច្ចទៅប្រទេសជឿនលឿនមួយចំនួន។